KHMER

# វិធីសាស្ត្រប្រឆាំងគ្រឿងញៀន នៅកាប្រាម៉ាតា

ប័ណ្ណពត៌មាន ■ 1 ខែកក្កដា ឆ្នាំ 2001

## តើអ្វីទៅដែលជាវិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា?

វិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា គឺជាផែនការទូលំទូលាយមួយ ដើម្បីដោះស្រាយបញ្ហាគ្រឿងញៀននិងឧក្រិដ្ឋកម្មនៅក្នុងកាប្រាម៉ាតា។

វិធីសាស្ត្រនេះ មានរួមបញ្ចូលនូវ :

- ចំនួនប៉ូលិសបន្ថែម  ដោយមានអំណាចថែមទៀត
- ការព្យាបាលសំរាប់អ្នកប្រើគ្រឿងញៀន និងការពង្រីកសេវា(កិច្ចបំរើ)ព្យាបាលនិងការអប់រំណែនាំអ្នកប្រើគ្រឿងញៀនឲ្យបានល្អឡើងវិញក្នុងតំបន់ស៊ីដនីប៉ែកនិរតី។
- ការពង្រីកបណ្តាកម្មវិធីបង្ការនិងអន្តរាគមន៍មុនពេល, និង
- កម្មវិធី City Watch (ឃ្លាំមើលក្រុង) ដើម្បីធ្វើឲ្យសហគមន៍និងប៉ូលិសធ្វើការរួមគ្នា  ក្នុងការបង្កើតដំណោះស្រាយទៅនឹងឧក្រិដ្ឋកម្មក្នុងតំបន់។

រដ្ឋាភិបាលបានលៃទុកប្រាក់បន្ថែមចំនួន 18លាន 8សែនដុល្លារសំរាប់ពេលបួនឆ្នាំ  ដើម្បីអនុវត្តវិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា។

ផែនការនេះគឺជាកិច្ចខិតខំដ៏ខ្លាំងក្លាបំផុត ដើម្បីធ្វើឲ្យកាប្រាម៉ាតាក្លាយទៅជាតំបន់មានសុវត្ថិភាព សំរាប់ប្រជាពលរដ្ឋដែលរស់នៅនិងធ្វើការនៅទីនោះ។

ភារកិច្ចនេះពុំមែនងាយស្រួលឡើយ។  គេពុំមានដំណោះស្រាយយ៉ាងរហ័សទេ។  ភារកិច្ចនេះនឹងតម្រូវឲ្យមានកិច្ចខិតខំពិតប្រាកដពីសំណាក់ជនរាក់វិនរាល់រូប និងការប្តូរផ្តាច់ពិតប្រាកដ ដើម្បីធ្វើការរួមគ្នា។



Premier Bob Carr

## ធនធាននិងអំណាចថ្មីសំរាប់ប៉ូលិស

វិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា ធានាឲ្យប៉ូលិសមានអំណាចនិងធនធានដែលគេត្រូវការ ដើម្បីដោះស្រាយឧក្រិដ្ឋកម្មទាក់ទងនឹងគ្រឿងញៀន។

### អំណាចថ្មីរបស់ប៉ូលិស

ប៉ូលិស NSW បានបង្កើនអំណាចនៅក្នុងបញ្ហាទាក់ទងនឹងផ្ទះគ្រឿងញៀន។  ការពិន័យទោសនិងច្បាប់ថ្មីទាំងនេះអនុវត្តពាសពេញរដ្ឋ។

- ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001  ប៉ូលិសមានអំណាចថ្មីដើម្បីចាប់ខ្លួន :
  - ជនណាមួយដែលចូលឬចេញពីផ្ទះដែលសង្ស័យថាមានគ្រឿងញៀន – លុះត្រាតែជនទាំងនោះអាចបង្ហាញនូវគោលបំណងស្របច្បាប់មួយ
  - បណ្តាម្ចាស់ឬអ្នករស់នៅក្នុងផ្ទះ ដែលអនុញ្ញាតឲ្យប្រើផ្ទះរបស់គេធ្វើជាផ្ទះគ្រឿងញៀនដោយចេតនា,  និង
  - ជនណាមួយដែលចាត់ចែងឬជួយក្នុងការរៀបចំផ្ទះគ្រឿងញៀនមួយ  ដូចជាការការឃ្លាំមើលផ្លូវជាដើម។
- ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001  ប៉ូលិសក៏មានអំណាចដើម្បីបញ្ជាឲ្យជនដែលប៉ូលិសសង្ស័យថា កំពុងមានបំណងរៀបចំការជួញដូរគ្រឿងញៀន ចេញពីទីកន្លែងណាមួយផងដែរ។
- ប៉ូលិសនឹងមានអំណាចថ្មីដើម្បីឆែករកមើលគ្រឿងញៀន។ អំណាចនេះនឹងមានរួមទាំងអំណាចដើម្បីឃុំខ្លួនបុគ្គលមួយ ហើយសុំឲ្យគ្រូពេទ្យឆែករកមើល  បើគេសង្ស័យថា បុគ្គលនោះបានលេប ឬលាក់បង្កប់គ្រឿងញៀននៅខាងក្នុងរាងកាយ។  ការឆែករកមើលមួយអាចនឹងធ្វើឡើងតាមរយៈដំណើរការថតរូបវេជ្ជសាស្ត្រ  ដូចជាថត X-ray, MRI (Magnetic Resonance Imaging), ultrasound, CAT Scans ។

  បើទម្រង់ការនេះបង្ហាញនូវវត្តមាននៃគ្រឿងញៀននៅខាងក្នុងរាងកាយរបស់ជនសង្ស័យ  ប៉ូលិសនឹងមានអំណាចឃុំឃាំងជនសង្ស័យនោះដល់ទៅ 48 ម៉ោង – រហូតទាល់តែគ្រឿងញៀនទាំងនោះចេញមកខាងក្រៅ។

### ច្បាប់ថ្មីលើកាំភ្លើងដៃ

ប៉ូលិសរាយការណ៍អំពីទំនាក់ទំនងរវាងការផ្គត់ផ្គង់គ្រឿងញៀនខុសច្បាប់ និង ការជួញដូរខុសច្បាប់នូវកាំភ្លើងដៃ។

ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ច្បាប់ថ្មីទាំងឡាយផ្តោតទៅលើការជួញដូរកាំភ្លើងដៃខុសច្បាប់  ហើយការពិន័យទោសបានកើនឡើង។ ច្បាប់នេះរួមទាំងកំណើននៃការពិន័យទោសដាក់ក្នុងពន្ធនាគារ ដោយតម្លើងពី 10 ទៅ 14 ឆ្នាំ ចំពោះការមានកម្មសិទ្ធិដោយខុសច្បាប់ នូវកាំភ្លើងវែងនិងកាំភ្លើងខ្លីដែលច្បាប់ហាមប្រាម។

**ការលើកលែងទោសទូទាំងរដ្ឋ**រយៈពេលបីខែ បានចាប់ផ្តើមពីថ្ងៃទី 29 ខែមិថុនា ឆ្នាំ 2001 ដើម្បីអនុញ្ញាតឲ្យចុះឈ្មោះកាំភ្លើងដៃ ឬប្រគល់ឲ្យប៉ូលិស។ នៅក្រោមការលើកលែងទោសនេះ  ជនណាមួយដែលគ្មានអាជ្ញាប័ណ្ណកាំភ្លើងដៃ អាចប្រគល់កាំភ្លើងដៃទៅឲ្យប៉ូលិសដោយគ្មានការបារម្ភអំពីការពិន័យទោស ឬការយកទៅកាត់ទោសឡើយ។ ការលើកលែងទោសនេះអនុវត្តសំរាប់កាំភ្លើងដៃទាំងអស់។  គេអាចប្រគល់កាំភ្លើងដៃនៅឯស្ថានីយការដ្ឋានប៉ូលិសណាមួយក៏បានដែរ។

បើលោកអ្នកមិនដឹងច្បាស់ថា តើកាំភ្លើងដៃមួយដែលស្ថិតនៅក្នុងកម្មសិទ្ធិរបស់លោកអ្នក មានចុះឈ្មោះដែរឬទេ  ឬមួយក៏ចង់បានពត៌មានថែមទៀត  សូមទាក់ទង **Firearms Registry Amnesty Information Line (ទូរស័ព្ទពត៌មានអំពីការលើកលែងទោស និងការចុះឈ្មោះកាំភ្លើងដៃ)** តាមទូរស័ព្ទដោយឥតគិតថ្លៃដែលមានលេខ **1300 557 772** ។

Produced by: Premier’s Department, New South Wales.

ActNow NSW GOVERNMENT AND YOU
Taking a stand against drugs

## ធនធានប៉ូលិស

ធនធានដែលមានសំរាប់ប៉ូលិសនៅកាប្រាម៉ាតា កំពុងតែបង្កើនឡើងដោយមានរួមទាំង :

- ភ្នាក់ងារប៉ូលិសចំនួន 108 នាក់ ដែលគ្រាសព្វថ្ងៃនេះស្ថិតនៅក្នុងទីបញ្ជាការតំបន់មូលដ្ឋាន (តម្លើងពី 84 នាក់ កាលពីឆ្នាំ 1995)
- អ្នកស៊ើបអង្កេតគ្រឿងញៀនចំនួនដប់នាក់ថែមទៀត
- ភ្នាក់ងារឃាមល្បាតតាមការជិះកង់ចំនួន 6 ថែមទៀត សំរាប់ការតបតដ៏រហ័សនៅតាមផ្លូវដើរតូចៗ និងតាមកម្រិតជងផ្លូវ។
- ភ្នាក់ងារប៉ូលិស 90 នាក់ មកពី Greater Hume Target Action Group (ក្រុមការងារគោលដៅ Greater Hume) និង
- Drug Detection Dogs (ឆ្កែស្រង់ក្លិនគ្រឿងញៀន)មួយក្រុម។

## អ្នកបកប្រែភាសាដើម្បីជួយប៉ូលិស

Community Relations Commission (គណៈកម្មការទំនាក់ទំនងសហគមន៍) កំពុងធ្វើការជាមួយប៉ូលិសនៅកាប្រាម៉ាតា ដើម្បីកែលំអសេវាបកប្រែភាសានៅគ្រប់ពេលម៉ោង។ អ្នកបកប្រែភាសាទាំងឡាយនឹងជួយប៉ូលិសក្នុងការធ្វើសំភាសន៍ជនសង្ស័យទាំងពួង, ការផ្តល់ជំនួយដល់ជនរងគ្រោះ, ការសាកសួរនិងការប្រាស្រ័យទាក់ទងជាប្រចាំជាមួយសហគមន៍ពាណិជ្ជកម្មក្នុងតំបន់។

## ការហ្វឹកហ្វឺនភាសានិងវប្បធម៌សំរាប់ប៉ូលិសក្នុងតំបន់

មន្ទីរប៉ូលិស NSW និង Department of Education and Training (ក្រសួងអប់រំនិងបណ្តុះបណ្តាល) កំពុងបង្កើតវគ្គសិក្សានៅ TAFE ដែលរៀបចំឡើងសំរាប់សេចក្តីត្រូវការពិសេស ហើយដែលនឹងផ្តល់ឲ្យប៉ូលិសកាប្រាម៉ាតានូវការហ្វឹកហ្វឺនយល់ដឹងអំពីវប្បធម៌និងជំនាញគោលការណ៍នៃភាសាផ្សេងៗក្រៅអំពីអង់គ្លេស។

### The City Watch Program (កម្មវិធីឃ្លាំមើលកាប្រាម៉ាតា)

Cabramatta City Watch នឹងកែលំអសុវត្ថិភាពនិងសមត្ថកិច្ចនៅក្នុងកាប្រាម៉ាតា ដោយធ្វើឲ្យប៉ូលិស, ពាណិជ្ជករក្នុងតំបន់ និងសហគមន៍ បង្កើតនូវដំណោះស្រាយទៅនឹងឧក្រិដ្ឋកម្មក្នុងតំបន់។

សមាជិកភាពនៃ Cabramatta City Watch Council (ក្រុមប្រឹក្សាឃ្លាំមើលក្រុងកាប្រាម៉ាតា) មានរួមទាំងមេបញ្ជាការតំបន់មូលដ្ឋាន (ប្រធាន), តំណាងរាស្ត្រប្រចាំតំបន់កាប្រាម៉ាតា, អភិបាលក្រុង Fairfield, ហើយនិងបណ្តាអ្នកតំណាងមកពីមន្ទីរពាណិជ្ជកម្មកាប្រាម៉ាតា, សមាគមពាណិជ្ជកម្មកាប្រាម៉ាតា, ក្រុមសហគមន៍ទាំងឡាយ, មន្ទីររបស់អភិបាលរដ្ឋ និង Community Relations Commission ។

Cabramatta City Watch Council នឹងធ្វើការជាមួយបណ្តាញមួយរបស់"បណ្តាក្រុមទំនាក់ទំនង"។ ក្រុមទំនាក់ទំនងនីមួយៗនឹងរួមបញ្ចូលសមាជិកទាំងឡាយនៃក្រុមចាប់អារម្មណ៍សហគមន៍មួយ, ភ្នាក់ងារប៉ូលិសម្នាក់ និងសមាជិកនៃ Community Relations Commission ។

*ដើម្បីទទួលពត៌មានថែមទៀតស្តីអំពីកម្មវិធី Cabramatta City Watch សូមទាក់ទង Rosa Droescher នៅឯ Community Relations Commission តាមទូរស័ព្ទលេខ 9716 2327 ។*

## ការព្យាបាលនិងការអប់រំណែនាំឲ្យបានល្អឡើងវិញ

ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 កម្មវិធីថ្មីពីរ – Police Drug Bail (ការធានាឲ្យនៅក្រៅឃុំនៃសមត្ថកិច្ចគ្រឿងញៀន) និង Magistrates Early Referral into Treatment (MERIT) (ការបញ្ជូនជាដំបូងដោយចៅក្រមឲ្យទទួលការព្យាបាល) – នឹងអនុវត្តនៅក្នុងកាប្រាម៉ា តា។ កម្មវិធីទាំងនេះតំរែតំរង់ឲ្យជនល្មើសទាំងឡាយដែលមានបញ្ហាគ្រឿងញៀន ឲ្យចូលទៅក្នុងសេវាព្យាបាលនិងការអប់រំណែនាំឲ្យបានល្អឡើងវិញ ដើម្បីបង្ការឧក្រិដ្ឋកម្មទាក់ទងនឹងគ្រឿងញៀនថែមទៀត ហើយដើម្បីកែលំអសុខភាពនិងសុខុមាលភាពរបស់បុគ្គលនោះ។

### Police Drug Bail (ការធានាឲ្យនៅក្រៅឃុំនៃសមត្ថកិច្ចគ្រឿងញៀន)

នៅក្រោម Police Drug Bail:

- បណ្តាអ្នករស់នៅក្នុងតំបន់ដែលជាប់ចោទពីបទល្មើសគ្រឿងញៀន អាចត្រូវបានពិនិត្យប៉ាន់ស្មង់សំរាប់ទទួលការព្យាបាលដើម្បីជាលក្ខខណ្ឌមួយនៃការធានាឲ្យនៅក្រៅឃុំ, ហើយ
- បើជននោះមកពីក្រៅតំបន់នេះ ការវិលទៅកាន់កាប្រាម៉ាតាវិញនឹងជាបទល្មើសទៅនឹងការធានាឲ្យនៅក្រៅឃុំ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទងប៉ូលិសកាប្រាម៉ាតា តាមទូរស័ព្ទលេខ 9725 8999 ។*

### Magistrates Early Referral into Treatment (MERIT) (ការបញ្ជូនជាដំបូងដោយចៅក្រមឲ្យទទួលការព្យាបាល)– កាប្រាម៉ាតា

Magistrates Early Referral into Treatment (MERIT) អនុញ្ញាតឲ្យចៅក្រមកំណត់ការព្យាបាលគ្រឿងញៀនជាលក្ខខណ្ឌមួយនៃការធានាឲ្យនៅក្រៅឃុំ។

អ្នកចូលរួមទាំងឡាយត្រូវបានគ្រប់គ្រងតាមករណីនីមួយៗយ៉ាងជិតដល់។ ចៅក្រមទទួលបណ្តារបាយការណ៍ជាទៀងទាត់ ស្តីអំពីការរីកចំរើនរបស់អ្នកចូលរួមទាំងនោះ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទងក្រុម MERIT ស៊ីដនីប៉ែកនិរតី តាមទូរស័ព្ទលេខ 9602 6777 ។*

## ការពង្រីកសេវាព្យាបាលនិងការអប់រំណែនាំឲ្យបានល្អឡើងវិញ

ជោគជ័យនៃកម្មវិធីទាំងឡាយ ដូចជា Police Drug Bail និង MERIT គឺអាស្រ័យទៅលើលទ្ធភាពទទួលការព្យាបាលមានប្រសិទ្ធ ភាព។ រដ្ឋាភិបាលកំពុងធ្វើការជាមួយសហគមន៍តំបន់ ដើម្បីបង្កើតសេវាព្យាបាលនិងការអប់រំណែនាំឲ្យបានល្អឡើងវិញថែមទៀត។

បណ្តាសេវាបន្ថែមដែលមាន នឹងរួមមាន :

- **Central Assessment Team (ក្រុមពិនិត្យប៉ាន់ស្មានទៅនឹងកណ្តាលមួយ)** នៅមន្ទីរពេទ្យ Fairfield ដើម្បីផ្តល់ផែនការព្យាបាលនិងពិនិត្យប៉ាន់ស្មង់។ សេវានេះនឹងបញ្ជូនអតិថិជនឲ្យចូលទៅក្នុងបណ្តាសេវាសុខភាព, ការព្យាបាលគ្រឿងញៀន និងសុខុមាលភាព។
- គ្រែព្យាបាលបីនៅមន្ទីរពេទ្យ Liverpool និងបួននៅ GROW, Austral សំរាប់អ្នកដែលមានបណ្តាបញ្ហាគ្រឿងញៀននិងសុខភាពផ្លូវចិត្តស្មុគស្មាញ។
- គ្រែព្យាបាលប្រាំបីថែមទៀតនៅមន្ទីរពេទ្យ Fairfield ដើម្បីផ្តល់ការអប់រំណែនាំឲ្យបានល្អឡើងវិញរយៈពេលខ្លី សំរាប់អតិថិជនដែលបញ្ជូនពីសេវាសុខភាពនិងព្យាបាលគ្រឿងញៀនឯទៀត។

គេនឹងមានសេវាព្យាបាលទាំងឡាយថែមទៀត។ រដ្ឋាភិបាលនឹងគ្រប់គ្រងដោយសមរម្យ ហើយនឹងចាត់ចែងសេវាទាំងនេះ។

**Treatment Services Monitoring Committee (គណៈកម្មាធិការតាមពិនិត្យបណ្តាសេវាព្យាបាល)** នឹងត្រូវបង្កើតឡើងដើម្បីតាមពិនិត្យប្រតិបត្តិការរបស់សេវាទាំងនេះ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទងអ្នកសំរបសំរួលគ្រឿងញៀននិងសុរាស៊ីដនីប៉ែកនិរតី តាមទូរស័ព្ទលេខ 9828 4877 ។*

## ទីកន្លែងផ្តល់ទីលំនៅពេលមានវិបត្តិ

Department of Housing (ក្រសួងទីលំនៅ) នឹងផ្តល់ទីលំនៅបន្ថែមសំរាប់ពេលមានវិបត្តិ ដោយរួមបញ្ចូលទាំង :

- ទីលំនៅបណ្តោះអាសន្នសំរាប់អតិថិជន នៅក្នុងពេលដែលស្វែងរកជំរើសទីលំនៅដទៃទៀត, និង
- ជំនួយសំរាប់អតិថិជន ដើម្បីជួលផ្ទះឯកជន។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទងការិយាល័យ Fairfield នៃ Department of Housing តាមទូរស័ព្ទលេខ 9754 6840 ។*

លើសពីនោះទៅទៀត គេមានផ្តល់ទីលំនៅរយៈពេលខ្លីចំនួនរហូតដល់ទៅ 40 និងរយៈពេលមធ្យមចំនួន 10 សំរាប់អតិថិជនដែលបញ្ជូនពីបណ្តាសេវាផ្តល់ជំនួយ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទង Hume Community Housing Association តាមទូរស័ព្ទលេខ 9724 0554 ។*

## កម្មវិធីបង្ការនិងអន្តរាគមន៍ទាន់ពេល

### Cabramatta Street Team (ក្រុមតាមដងផ្លូវកាប្រាម៉ាតា)

ក្រុមមួយដែលមានគ្នាប្រាំពីរនាក់របស់ Department of Community Services (ក្រសួងសេវាសហគមន៍) នឹងជួយជនជំទង់និងអ្នកដទៃដែលមានបញ្ហាគ្រឿងញៀន។ ក្រុមនេះនឹង :

- ជួយធ្វើឲ្យគេមានទំនាក់ទំនងជាមួយនឹងគ្រួសារឡើងវិញ, ហើយ
- បញ្ជូនអ្នកគ្មានទីជំរកទៅកាន់សេវានានាដែលនឹងជួយជននេះ។

ក្រុមនេះនឹងធ្វើដំណើរទៅកាន់កន្លែងទាំងឡាយដែលនិយមចូលចិត្តដោយយុវជនក្នុងកាប្រាម៉ាតា ហើយក៏នឹងមានទីតាំងនៅឯស្ថានីយការដ្ឋានប៉ូលិសកាប្រាម៉ាតាផងដែរ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទង Fairfield Community Service Centre, Department of Community Services តាមទូរស័ព្ទលេខ 9728 1911 ។*

### Gateways (ផ្លូវចេញចូល)

**Gateways** គឺជាកម្មវិធីបង្ការមួយដែលផ្តល់ការអប់រំគ្រឿងញៀនសំរាប់សិស្សបឋមសិក្សានិងមធ្យមសិក្សាទាំងអស់ ក្នុងតំបន់កាប្រាម៉ាតា។ កម្មវិធីនេះក៏ផ្តល់ជំនួយថែមទៀតសំរាប់សិស្សសាលា មធ្យមសិក្សា ដែលអាចមានបញ្ហាក្នុងការមិនបញ្ចប់សព្វគ្រប់នូវថ្នាក់ Year 12 ឬអាចមានបញ្ហាក្នុងការប្រើគ្រឿងញៀនខុសច្បាប់ទាំងឡាយ។

ចាប់ពីត្រីមាសទីបីនៃឆ្នាំ 2001, សិស្ស"ដែលអាចមានបញ្ហា" 600 នាក់ នឹងទទួលការគ្រប់គ្រងតាមករណីនីមួយៗ ដោយរួមទាំងផែនការអប់រំបុគ្គលនីមួយៗ ដើម្បីកែលំអជំនាញអក្ខរកម្មនិងការចេះគិតលេខរបស់គេ, ការទៅរៀន និងទម្លាប់ធ្វើកិច្ចការគ្រូដាក់ឲ្យធ្វើនៅផ្ទះ។

ដើម្បីផ្តល់ការគាំទ្រថែមទៀត គ្រូបង្រៀនជាង 70 នាក់ កំពុងទទួលការបណ្តុះបណ្តាលឲ្យធ្វើជាអ្នកគ្រប់គ្រងណែនាំសិស្ស។

Department of Education and Training ក៏នឹងផ្តល់ **Drug Education Consultant (អ្នកពិគ្រោះយោបល់អប់រំគ្រឿងញៀន)** ម្នាក់ថែមទៀតដើម្បីផ្តល់ជំនួយលើការអប់រំគ្រឿងញៀនក្នុងសាលារដ្ឋទាំងអស់ នៅក្នុងស្រុក។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទង Department of Education and Training តំបន់ Fairfield តាមទូរស័ព្ទលេខ 9793 4900 ។*

### Primary Connect (ការទាក់ទងសំខាន់)

កម្មវិធីថ្មី **Primary Connect** របស់សាលារៀន នឹងត្រូវសាកល្បងឡើងនៅតាមសាលាបឋមសិក្សាមួយចំនួនតូច ដោយមានរួមទាំងតំបន់កាប្រាម៉ាតា។ Primary Connect នឹងផ្តល់ការបណ្តុះបណ្តាលយុវជន សំរាប់អ្នកមានអាយុ 5-12 ឆ្នាំ និងជំនួយថែទាំកូនសំរាប់គ្រួសាររបស់គេ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទង Department of Education and Training តាមទូរស័ព្ទលេខ 9561 8311 ។*

### Families First (គ្រួសារជាមុន)

កម្មវិធី **Family First** នឹងគាំទ្រគ្រួសារចំនួន 100 គ្រួសារដែលមានកូនអាយុតិចជាង 8 ឆ្នាំ នៅក្នុងកាប្រាម៉ាតា, Canley Vale, Bonnyrigg និង Fairfield ។

នៅក្រោមកម្មវិធីនេះ សាលាទាំងឡាយក្នុងតំបន់ ក្លាយជាមជ្ឈមណ្ឌលសំរាប់មាតាបិតានិងសហគមន៍ ដោយផ្តល់ :

- ឱកាសសំរាប់ឲ្យគ្រួសារទាំងឡាយជួបគ្នាទៅវិញទៅមក
- ការទាក់ទងនឹងសេវាទាំងឡាយក្នុងសហគមន៍តំបន់
- ពត៌មានស្តីអំពីការថែទាំកូននិងការលូតលាស់នៃកុមារភាព, ហើយនិង
- ពត៌មានស្តីអំពីប្រព័ន្ធសាលារៀន និងរបៀបគាំទ្រកូនក្នុងការរៀបចំសំរាប់ការសិក្សានៅសាលារៀន។

កម្មវិធីនេះនឹងមាននៅក្នុងអម្លុងត្រីមាសទីបួន នៃឆ្នាំ 2001 ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទង Families First តាមទូរស័ព្ទលេខ 9797 8133 ។*

### Cabramatta Mobile Child Care and Family Counselling Service (សេវាចល័តថែទាំកុមារនិងប្រឹក្សាឱវាទគ្រួសារកាប្រាម៉ាតា)

ចាប់ពីខែកញ្ញា ឆ្នាំ 2001, Uniting Care-Burnside (ការថែទាំរួម - Burnside) ទទួលថវិកាដើម្បីផ្តល់សេវាប្រឹក្សាឱវាទគ្រួសារ, ការគាំទ្រយ៉ាងល្អិតល្អន់សំរាប់គ្រួសារ និងសេវាចល័តថែទាំកុមារដើម្បីជួយគ្រួសារចំនួន 350 គ្រួសារថែមទៀត នៅក្នុងតំបន់ជារៀងរាល់ឆ្នាំ។

### Family Counselling Service (សេវាប្រឹក្សាឱវាទគ្រួសារ)

នឹងផ្តល់ការប្រឹក្សាឱវាទ នៅក្នុងទីកន្លែងមួយដែលអ្នកទទួលជំនួយនិងគ្រួសាររបស់គេមានអារម្មណ៍កក់ក្តៅបំផុត។ ទីកន្លែងនេះអាចរួមទាំងទីលំនៅរបស់គ្រួសារ។

## គំរោងការងារកន្លែងកាប្រាម៉ាតា (Cabramatta Place Project)

នៅខែមេសា ឆ្នាំ 1997 ដោយធ្វើកិច្ចសហការជាមួយសាលាក្រុង Fairfield និងអង្គការទាំងឡាយឯទៀត មន្ទីររបស់អភិបាលរដ្ឋបានបង្កើត **Cabramatta Place Project** ដើម្បីដោះស្រាយការប្រើគ្រឿងញៀនខុសច្បាប់ និងផលប៉ះពាល់របស់វាទៅលើសហគមន៍កាប្រាម៉ាតា។

**វិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា** ប្រើស្នាដៃទាំងឡាយរបស់ Cabramatta Place Project និងកិច្ចការរបស់ Fairfield Community Drug Action Team ដើម្បីធ្វើជាមូលដ្ឋានពង្រឹង (សូមមើលទំព័រម្ខាងទៀត)។

គំរោងការងារនេះបានរួមចំណែកដល់លទ្ធផលវិជ្ជមានទាំងពួងដោយមានរួមទាំង :

- សុវត្ថិភាពថែមទៀតសំរាប់សហគមន៍
- ទំនាក់ទំនងប្រសើរឡើងជាមួយនឹងប៉ូលិស
- ការព្យាបាលថែមទៀតសំរាប់អ្នកប្រើគ្រឿងញៀននិងស្រា
- ឱកាសការងារនិងបណ្តុះបណ្តាលថែមទៀតសំរាប់យុវជន
- ការផ្សព្វផ្សាយកាប្រាម៉ាតា ជាទិសដៅទេសចរណ៍
- ដងផ្លូវនានាដែលកាន់តែស្អាតស្អំនិងមានសុវត្ថិភាពឡើង។

ជាផ្នែកនៃដំណាក់កាលទីពីររបស់គំរោងការងារនេះ មន្ទីររបស់អភិបាលរដ្ឋកំពុងនាំមុខនិងជួយសំរួលដល់ Cabramatta Anti-Drug Strategy ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទងប្រធានជាន់ខ្ពស់នៃគំរោងការងារ, Cabramatta Place Project តាមទូរស័ព្ទលេខ 9724 7811 ។*

**Intensive Family Support** (**ការគាំទ្រយ៉ាងល្អិតល្អន់សំរាប់គ្រួសារ**) នឹងធ្វើការកាន់តែជិតស្និទ្ធឡើងជាមួយនឹងគ្រួសារនានា ដោយឲ្យគេមានទំនាក់ទំនងជាមួយសេវាទាំងពួងដែលគេត្រូវការ ដើម្បីជួយគេក្នុងបញ្ហាគ្រឿងញៀនរបស់សមាជិកគ្រួសារ។

ដើម្បីជួយគ្រួសារទាំងឡាយឲ្យទទួលនូវកម្មវិធីទាំងនេះ **Mobile Child Care Service** (**សេវាចល័តថែទាំកុមារ**) នឹងផ្តល់ការថែទាំកុមារចំពោះគ្រួសារទាំងឡាយ ដែលចូលរួមសេវាពិគ្រោះយោបល់ និងផ្តល់ជំនួយល្អិតល្អន់។

Intensive Family Support និង Family Counselling ធ្វើការតាមការបញ្ជូនពី Cabramatta Street Team ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទង Department of Community Services តាមទូរស័ព្ទលេខ 9797 8133 ។*

## ពត៌មាននិងសកម្មភាពសហគមន៍

### Youth Action Team (ក្រុមសកម្មភាពយុវជន)

Cabramatta Place Project (គំរោងការងារកន្លែងកាប្រាម៉ាតា) បានបង្កើត **Youth Action Team** (**ក្រុមសកម្មភាពយុវជន**) ដើម្បីសំរបសំរួលសេវាទាំងឡាយឲ្យបានប្រសើរឡើងសំរាប់យុវជន ហើយដើម្បីធ្វើការកែលំអ :

- ឱកាសកំសាន្តនិងកីឡា
- ទំនាក់ទំនងប៉ូលិសនិងយុវជន, ហើយនិង
- សេវាទីលំនៅ, សុខភាព និងជំនួយដទៃទៀត។

ក្រុមនេះរួមមានអ្នកតំណាងទាំងឡាយរបស់រដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទងប្រធានជាន់ខ្ពស់នៃគំរោងការងារ, Cabramatta Place Project តាមទូរស័ព្ទលេខ 9724 7811 ។*

### Multicultural Drug Education Program (កម្មវិធីអប់រំគ្រឿងញៀនពហុវប្បធម៌)

នៅក្នុងកាប្រាម៉ាតា វាជាការចាំបាច់ដាច់ខាតដែលធនធានអប់រំគ្រឿងញៀនទាំងឡាយ ត្រូវធ្វើទៅតាមសេចក្តីត្រូវការរបស់សហគមន៍ដែលមានសាវតារមិននិយាយអង់គ្លេស (NESB) ។

កម្មវិធី **Multicultural Drug Education** នឹង :

- ផលិតសំភារៈឯកសារជាពហុភាសា ដោយផ្តល់ឱវាទសំរាប់ប្រតិបត្តិស្តីអំពីការដោះស្រាយបញ្ហាទាក់ទងនឹងគ្រឿងញៀន
- ជួយបណ្តាសាលារៀន, ទីភ្នាក់ងារក្នុងតំបន់ និង Fairfield Drug Action Team ដើម្បីធ្វើការជាមួយបណ្តាសហគមន៍ NESB ។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទងប្រធានជាន់ខ្ពស់នៃគំរោងការងារ, Cabramatta Place Project តាមទូរស័ព្ទលេខ 9724 7811 ។*

### Drugs and Community Action Strategy (វិធីសាស្ត្រសកម្មភាពសហគមន៍និងគ្រឿងញៀន)

**Drugs and Community Action Strategy** បានត្រូវបង្កើតឡើងដោយសារតែជាលទ្ធផលនៃសន្និសិទកំពូលអំពីគ្រឿងញៀន NSW កាលពីឆ្នាំ 1999 ។ វិធីសាស្ត្រនេះជួយបង្កើតបណ្តាក្រុមនិងភាពជាដៃគូក្នុងតំបន់ – Community Drug Action Teams (CDATs) (បណ្តាក្រុមសកម្មភាពគ្រឿងញៀនសហគមន៍) – ដើម្បីធ្វើការជាមួយសហគមន៍ទាំងពួង ក្នុងការឆ្លើយតបទៅនឹងបញ្ហាគ្រឿងញៀនទាំងឡាយក្នុងតំបន់។

Fairfield CDAT បានត្រូវបង្កើតឡើងនៅឆ្នាំ 1997 ។ ជោគជ័យរបស់ក្រុមនេះបានរួមចំណែកដល់ការបង្កើតវិធីសាស្ត្រនោះ។ក្រុមនេះបានផ្តួចផ្តើមឲ្យមានគំរោងការងារមួយចំនួន ដូចជា Café Horizons, Adra Café និងផលិតកម្មនៃឯកសារពត៌មានពហុភាសា *Drugs, Young People and the Law* (គ្រឿងញៀន, យុវជន និងច្បាប់)។

*ដើម្បីទទួលពត៌មានថែមទៀត សូមទាក់ទងប្រធានគំរោងការងារនៅស៊ីដនីប៉ែកនិរតី តាមទូរស័ព្ទលេខ 9793 1577 ឬបើកមើលអ៊ីនធឺណិតរបស់ Drugs and Community Action Strategy www.communitybuilders.nsw.gov.au/drugs_action*

### ការពង្រីកក្រុមបោសសំអាតសឺរាំង

ជនល្មើសទាំងឡាយដែលត្រូវអនុវត្តតាម Periodic Detention Orders (ដីកាឃុំឃាំងតាមកាលកំណត់) ធ្វើការដើរល្បាតជាប្រក្រតីដើម្បីយកម្ជុលបោះចោលទាំងឡាយចេញពីដងផ្លូវ។ កម្មវិធីនេះនឹងត្រូវពង្រីកឡើង។

បើលោកអ្នកជួបប្រទះនឹងម្ជុលបោះចោល សូមទូរស័ព្ទទៅកាន់ **Needle Clean Up Hotline** (**ទូរស័ព្ទបោសសំអាតម្ជុល**) ដែលឥតគិតថ្លៃ តាមលេខ **1800 633 353** ។

## ពត៌មានថែមទៀត

### តើត្រូវការជំនួយឬទេ?

បើលោកអ្នកឬនរណាម្នាក់ដែលលោកអ្នកស្គាល់ ត្រូវការជំនួយ ឬឱវាទលាក់ការណ៍សម្ងាត់អំពីគ្រឿងញៀន សូមទូរស័ព្ទទៅកាន់ **Alcohol and Drug Information Service (ADIS)** (សេវាពត៌មានសុរានិងគ្រឿងញៀន ADIS) តាមលេខ **9361 8000** (តំបន់ទីក្រុងស៊ីដនីតែប៉ុណ្ណោះ) ឬទូរស័ព្ទឥតគិតថ្លៃតាមលេខ **1800 422 599** (នៅក្រៅក្រុងស៊ីដនី)។

ADIS ធ្វើការ 24 ម៉ោងក្នុងមួយថ្ងៃដោយផ្តល់ឱវាទ, ពត៌មាន និងការបញ្ជូនដោយលាក់ការណ៍សម្ងាត់ទៅកាន់អង្គការក្នុងតំបន់។

ក្នុងភាពជាមាតាឬបិតា ការដោះស្រាយបញ្ហាគ្រឿងញៀនទាំងពួងអាចជាការលំបាកខ្លាំង។ ដើម្បីទទួលឱវាទអំពីរបៀបនិយាយទៅកាន់យុវជនស្តីអំពីបណ្តាបញ្ហានៃការប្រើគ្រឿងញៀន ឬ អាកប្បកិរិយា សូមទាក់ទង **Parent Line** (ទូរស័ព្ទសំរាប់មាតាបិតា) តាមទូរស័ព្ទឥតគិតថ្លៃ លេខ **13 20 55** ។

### ការរាយការណ៍អំពីឧក្រិដ្ឋកម្មគ្រឿងញៀន

ពត៌មានណាមួយដែលលោកអ្នកមានអំពីឧក្រិដ្ឋកម្មគ្រឿងញៀន ទោះជាលោកអ្នកគិតថាវាមិនសំខាន់ក៏ដោយ ក៏វាអាចជួយឲ្យប៉ូលិសក្នុងការចាប់ខ្លួនឧក្រិដ្ឋជនដែរ។ ដើម្បីរាយការណ៍នូវឧក្រិដ្ឋកម្មទាក់ទងនឹងគ្រឿងញៀន សូមទូរស័ព្ទទៅកាន់ **Crime Stoppers** តាមទូរស័ព្ទឥតគិតថ្លៃ លេខ **1800 333 000** ។

### តើចង់ដឹងថែមទៀតឬទេ?

បើលោកអ្នកចង់បានពត៌មានថែមទៀតអំពីវិធានការតបតរបស់រដ្ឋាភិបាល NSW ទៅនឹងបញ្ហាគ្រឿងញៀន សូមបើកមើលអ៊ីនធឺណិត **www.druginfo.nsw.gov.au** ។

នៅនឹង **www.druginfo.nsw.gov.au** លោកអ្នកនឹងឃើញពត៌មានថែមទៀតអំពីគ្រឿងញៀន, គំរោងការងារ និងវិធានការដែលធ្វើឡើងដើម្បីដោះស្រាយបញ្ហាគ្រឿងញៀនទាំងឡាយ។ អ៊ីនធឺណិតនេះក៏មានសំណៅ Drug Summit Plan of Action (ផែនការសកម្មភាពរបស់សន្និសិទកំពូលអំពីគ្រឿងញៀន) របស់រដ្ឋាភិបាល NSW, ប្រភពជំនួយ និងការតភ្ជាប់ផ្សេងៗទៅកាន់អ៊ីនធឺណិតវ៉ាក់វិនឯទៀតផងដែរ។